## រឿងទី៣៖
## ព្រះយេស៊ូស្រឡាញ់ក្មេងៗ

**ខគម្ពីរ៖**
**ម៉ាថាយ១៩:១៤**

នោះព្រះយេស៊ូវទ្រង់មានព្រះបន្ទូលថា ទុកឱ្យកូនក្មេងមកឯខ្ញុំចុះ កុំឃាត់វាឡើយ
ដ្បិតនគរស្ថានសួគ៌មានសុទ្ធតែមនុស្សដូចវាគាល់គ្នា

ព្រះយេស៊ូបានយាងមកដល់ភូមិយូដាជាមួយពួកសិស្ស ដើម្បីផ្សាយដំណឹងល្អពីនគរព្រះជាម្ចាស់។
គ្រប់កន្លែងដែលព្រះយេស៊ូយាងទៅ តែងតែមានមនុស្សមកប្រមូលផ្តុំគ្នាយ៉ាងច្រើន។
ហើយក្នុងនោះ ក៏មានឪពុកម្តាយដែលបាននាំកូនៗមកជាមួយផងដែរ។
ក្មេងៗសប្បាយចិត្តខ្លាំងណាស់ ដោយព្រោះគិតថាបានជួបព្រះយេស៊ូ!
ពួកគេបានឃើញព្រះយេស៊ូ!
ក្មេងៗបានរត់យ៉ាងលឿន ដើម្បីចូលទៅជិតព្រះយេស៊ូ។
ប៉ុន្តែ នៅពេលដែលក្មេងៗព្យាយាមទៅរកព្រះយេស៊ូ ស្រាប់តែពួកសិស្សបានឃាត់ក្មេងៗនិងឪពុកម្តាយពួកគេ
ព្រះយេស៊ូបានទតឃើញទិដ្ឋភាពនោះ ទ្រង់ក៏បានបន្ទោសពួកសិស្សថា៖
"ទុកឱ្យក្មេងៗមកឯខ្ញុំចុះ! កុំឱ្យឃាត់វាឡើយ! នគរស្ថានសួគ៌មានសុទ្ធតែមនុស្សដូចវាគាល់គ្នាដែរ! ឱ ពួកសិស្សទាំងអស់គ្នាអើយ ខ្ញុំសូមប្រាប់អ្នកទាល់គ្នាឱ្យដឹងច្បាស់ថា
ចូរជឿលើនគរព្រះជាម្ចាស់ដូចជាក្មេងតូចនេះ! អ្នកណាមិនព្រមទទួលព្រះរាជ្យព្រះជាម្ចាស់ដូចក្មេងតូចមួយទេ អ្នកនោះចូលក្នុងព្រះរាជ្យព្រះអង្គមិនបានឡើយ។"
ព្រះយេស៊ូបានលាព្រះហស្តទាំងពីរទទួលក្មេងៗ។ ព្រះយេស៊ូបានឱបក្មេងៗ ហើយបានដាក់ព្រះហស្តប្រទានពរដល់ពួកគេ។
គ្រប់ទីកន្លែងដែលព្រះយេស៊ូយាងទៅ ទ្រង់តែងតែផ្តល់ក្តីស្រឡាញ់ដល់ក្មេងៗ ទ្រង់មិនធុញទ្រាន់នឹងពួកគេឡើយ។





**សកម្មភាពទី១** សូមឆ្លើយសំណួរខាងក្រោម។

a. តើព្រះយេស៊ូបានយាងទៅដល់ភូមិណាជាមួយពួកសិស្សរបស់ព្រះអង្គ?

---------------------------------------------------------------------------

b. តើអ្នកណាខ្លះបានរាំងកុមារមិនឱ្យមកជិតព្រះយេស៊ូ?

---------------------------------------------------------------------------

c. សូមអានព្រះគម្ពីរម៉ាថាយ១៩៖១៣ រួចឆ្លើយសំណួរ។ តើឪពុកម្ដាយបាននាំកូនមកព្រះយេស៊ូ ចង់ឱ្យព្រះអង្គធ្វើអ្វីដល់កូនៗរបស់ពួកគេ?

---------------------------------------------------------------------------

- សូមអានខគម្ពីរ និងទន្ទេញខគម្ពីរ។ (ម៉ាថាយ១៩៖១៤)

**ព្រះយេស៊ូមានព្រះបន្ទូលថា ទុកឱ្យកូនក្មេងមកឯខ្ញុំចុះ កុំឃាត់វាឡើយ។**

**សកម្មភាពទី២**

តើផ្លូវណាដែលកុមារត្រូវជ្រើសរើស ដើម្បីទៅជួបព្រះយេស៊ូ?
សូមជ្រើសរើសលេខណាមួយ ក្នុងចំណោមលេខ1-6 ដែលនឹងនាំអ្នកទៅជួបព្រះយេស៊ូ។ ផ្លាស់ទីពីឆ្វេងទៅស្ដាំ
ហើយនៅពេលអ្នកជួបបន្ទាត់បញ្ឈរ សូមរំកិលឡើងលើ ឬចុះក្រោមរហូតដល់ជួបព្រះយេស៊ូ។

